ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

EAC

អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ ៤២៧/សជណ.១៧/អអក

ភ្នំពេញ, ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
## ស្តីពីការពិគ្រោះយោបល់សាធារណៈក្នុងការកែសម្រួលអាជ្ញាបណ្ណរបស់ លោកស្រី ប៉ែន ចាន់ណា សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកកំពង់ស្វាយ ស្រុកប្រាសាទបល្ល័ង្គ ស្រុកប្រាសាទសំបូរ និងក្រុងស្ទឹងសែន ខេត្តកំពង់ធំ

អាជ្ញាធរអគ្គិសនីកម្ពុជាមានកិត្តិយសសូមជម្រាបជូនសាធារណជននៅស្រុកកំពង់ស្វាយ ស្រុកប្រាសាទបល្ល័ង្គ ស្រុកប្រាសាទសំបូរ និងក្រុងស្ទឹងសែន ខេត្តកំពង់ធំ ឲ្យបានជ្រាបថា អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណរបស់លោកស្រី ប៉ែន ចាន់ណា ដើម្បីអនុញ្ញាតឲ្យពង្រីកតំបន់ចែកចាយអគ្គិសនីបន្ថែមលើតំបន់ចែកចាយដែលមានស្រាប់ តាមខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណ ដូចមានជូនភ្ជាប់មកជាមួយនេះ ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការកែសម្រួលអាជ្ញាបណ្ណ អាជ្ញាធរមូលដ្ឋាន ស្ថាប័ននានាដែលពាក់ព័ន្ធ និងសាធារណជនមានសិទ្ធិពិនិត្យ ផ្តល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាលើខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណដែលគ្រោងផ្តល់ជូនលោកស្រី ប៉ែន ចាន់ណា ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណនៅ.................................................................................................................................................................... សម្រាប់សាធារណជនពិនិត្យ ។

អាស្រ័យហេតុនេះ សូមសាធារណជននៅស្រុកកំពង់ស្វាយ ស្រុកប្រាសាទបល្ល័ង្គ ស្រុកប្រាសាទសំបូរ និងក្រុងស្ទឹងសែន ខេត្តកំពង់ធំ ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬផ្តល់យោបល់លើខ្លឹមសារនៃការចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណឲ្យលោកស្រី ប៉ែន ចាន់ណា អាចអញ្ជើញមកទីកន្លែងខាងលើដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្តល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះ រហូតដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ ។ អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា **"អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណា ដែលមានបង្ហាញនូវហេតុផលយ៉ាងច្បាស់លាស់ប៉ុណ្ណោះ"** ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

បណ្ឌិត.ទី នរិន្ទ

**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
**ទូរស័ព្ទ** : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ **ទូរសារ** : ០២៣ ២១៤ ១៤៤, **អ៊ីម៉ែល** : admin@eac.gov.kh ; Website : www.eac.gov.kh

សេចក្តីព្រាង

អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA

ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
ELECTRICITY LAW OF THE KINGDOM OF CAMBODIA

# សេចក្តីសម្រេចកែសម្រួលលើកទី២
# លើឯកសារអាជ្ញាបណ្ណលេខ ៣៨៧ ឯអ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ សម្រាប់លោកស្រី ប៉ែន ចាន់ណា ធ្វើសេវាកម្មអគ្គិសនី នៅផ្នែកខ្លះនៃស្រុកកំពង់ស្វាយ ស្រុកប្រាសាទបល្ល័ង្គ ស្រុកប្រាសាទសំបូរ និងក្រុងស្ទឹងសែន ខេត្តកំពង់ធំ

## សម្រាប់ការពង្រីកតំបន់ចែកចាយ

# DECISION ON THE SECOND REVISION

OF THE LICENSE DOCUMENT No.387 LD DATED JUNE 13, 2014
OF MRS. PEN CHANNA FOR PROVIDING ELECTRIC POWER SERVICE AT
SOME PART OF KAMPONG SVAY, PRASAT BALANG, PRASAT SAMBOR
DISTRICTS AND KRONG STUNG SEN, KANPONG THOM PROVINCE

## FOR EXTENDING DISTRIBUTION AREA

ថ្ងៃទី... ខែ... ឆ្នាំ២០១៧

..., 2017